# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបសមាជិកព្រឹទ្ធសភា នៃប្រទេសជប៉ុន



នៅព្រឹកថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបពិភាក្សាការងារជាមួយសមាជិកព្រឹទ្ធសភា នៃប្រទេសជប៉ុន រួមមានឯកឧត្តម **Masayuki NAOSHIMA** សមាជិកព្រឹទ្ធសភា និងជាអតីត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន និងឯកឧត្តម **Teruhiko MASHIKO** សមាជិកព្រឹទ្ធសភា និងជាអតីត អនុរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន ព្រមទាំងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។






ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងការស្វាគមន៍ និងបានចាត់ទុកដំណើរទស្សនៈកិច្ចការងារ របស់ឯកឧត្តម សមាជិកព្រឹទ្ធសភា ជប៉ុន នៅកម្ពុជា នាឱកាសនេះ នឹងពង្រីកបាននូវទំនាក់ទំនង និងកិច្ចសហការល្អថែមទៀត ជាពិសេសការជួយទាក់ទាញឱ្យអ្នកវិនិយោគទុនជប៉ុនមកបណ្តាក់ទុននៅកម្ពុជាកាន់តែច្រើនឡើង ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានថ្លែងអំណរគុណដល់ប្រទេសជប៉ុន ដែលជាប្រទេសបានដើរតួយ៉ាងសំខាន់ ក្នុងការរួមចំណែកស្វែងរកសន្តិភាព និងការអភិវឌ្ឍន៍នៅកម្ពុជា ជាពិសេសជំនួយអភិវឌ្ឍន៍របស់ប្រទេសជប៉ុន ដូចជាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ជាដើម គឺស្ថិតនៅក្នុងការចងចាំក្នុងបេះដូងរបស់ប្រជាជនកម្ពុជា ជានិច្ច ។

ឯកឧត្តម **Masayuki NAOSHIMA** និងឯកឧត្តម **Teruhiko MASHIKO** សមាជិកព្រឹទ្ធសភា នៃប្រទេសជប៉ុន បានសម្តែងទឹកចិត្តរីករាយចំពោះការបំពេញទស្សនៈកិច្ចជាលើកទី១ នៅកម្ពុជា និងបានជួបពិភាក្សាការងារ ជាមួយឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ដែលជាឥស្សរៈជនកម្ពុជាមួយរូបមានបទពិសោធន៍ ជិត២០ឆ្នាំ ក្នុងតំណែង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ហើយបច្ចុប្បន្នបានកាន់តំណែងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលឯកឧត្តមមានជំនឿថា ក្រសួងនេះនឹងសម្រេចបាននូវសមិទ្ធផលតាមការរំពឹងទុក ។ ឯកឧត្តម បានថ្លែងអំណរគុណចំពោះទឹកចិត្តដ៏ប្រពៃរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលតែងតែជួយរំលែកទុក្ខ និងឧបត្ថម្ភជាថវិកា ដល់រាជរដ្ឋាភិបាលជប៉ុន ដែលតែងតែជួបប្រទះនូវគ្រោះធម្មជាតិញឹកញាប់ ជាពិសេស គឺរលកយក្ស ស៊ូណាមិ ។ ឯកឧត្តម សមាជិកព្រឹទ្ធសភានៃប្រទេសជប៉ុន បានបង្ហាញនូវការមើលឃើញពីការរីកចម្រើនរបស់កម្ពុជា ហើយនឹងខិតខំជួយទាក់ទាញអ្នកវិនិយោគជប៉ុនពិនិត្យលទ្ធភាពវិនិយោគនៅកម្ពុជា ឱ្យកាន់តែច្រើនឡើងថែមទៀត ជាពិសេស គឺសហគ្រាសខ្នាតតូច និងមធ្យមរបស់ជប៉ុន ។ ជាមួយគ្នានេះ ភាគីជប៉ុនក៏បានជម្រាបជូនថាៈក្នុងដំណើរទស្សនៈកិច្ចនេះ ប្រតិភូរបស់លោក ក៏នឹងពិនិត្យមើលពីដំណើរការនៃគម្រោងវិនិយោគសាងសង់មន្ទីរពេទ្យជប៉ុនតាមកិរិតស្តង់ដា នៅទីក្រុងភ្នំពេញផងដែរ ។ ទាក់ទង និងវិស័យឧស្សាហកម្មរោងចក្រ ភាគីជប៉ុនបានបង្ហាញនូវសក្តានុពលរបស់កម្ពុជា លើវិស័យនេះ ជាពិសេសគឺកំលាំងពលកម្មកម្ពុជា ដែលភាគច្រើនជាកំលាំងយុវវ័យ ដែលមានការអត់ធ្មត់ និងប្រឹងប្រែងលើការងារ ។ ទាក់ទង និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច សម្រាប់

តំបន់អាស៊ាន និងអាស៊ីបូព៌ា (ERIA)ភាគីជប៉ុន បានចាត់ទុកវិទ្យាស្ថាននេះមានសារៈសំខាន់ណាស់ ក្នុងក្របខ័ណ្ឌ សមាហរណកម្មអាស៊ាន និងការបញ្ចប់កិច្ចព្រមព្រៀងដៃគូសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ក្នុងតំបន់ ដែលភាគីជប៉ុនស្នើឱ្យមានការគាំទ្រវិទ្យាស្ថាននេះបន្តទៀត ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសាទរចំពោះការសាងសង់មន្ទីរពេទ្យខ្នាតអន្តរជាតិ ក្រោមគម្រោងវិនិយោគរបស់ជប៉ុន ស្របនឹងគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ទាក់ទង និងវិទ្យាស្ថាន ERIA ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈឯកឧត្តម មានការគាំទ្រជាខ្លាំងចំពោះវិទ្យាស្ថាននេះតាំងពីដើមរៀងមក និងក៏បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការដឹកនាំរបស់ប្រធានវិទ្យាស្ថាននេះ ។ ឯកឧត្តម បានបន្ថែមថាៈ ក្នុងឱកាសកម្ពុជា ធ្វើជាប្រធានអាស៊ាន នៅឆ្នាំ២០១២ ហើយក្នុងនាម ឯកឧត្តម ជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ឯកឧត្តម បានស្នើឱ្យសមាជិកអាស៊ានទាំងអស់គាំទ្រដល់វិទ្យាស្ថាននេះ ដែលបច្ចុប្បន្នវិទ្យាស្ថាននេះ បានទទួលថវិកាឧបត្ថម្ភមួយចំណែក ពីប្រទេសជាសមាជិកអាស៊ាន ។ ទោះជាយ៉ាងណា ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានស្នើឱ្យភាគីជប៉ុន ជាពិសេស ក្រសួង សេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុន ជួយឧបត្ថម្ភដល់វិទ្យាស្ថាននេះប្រចាំឆ្នាំ ដើម្បីឱ្យ ERIA មានឯករាជ្យភាពខាងថវិកាផង និងបំពេញកិច្ចការកាន់តែមានប្រសិទ្ធិភាព ។

